# II. ទីស្ដីការ គណៈរដ្ឋមន្ត្រី

## ១- អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ១៩៩៤

## អនុក្រឹត្យលេខ ២១ អនក្រ ស្ដីពីការ
## បែងចែកខ្ទង់ចំណាយ មិនបានគ្រោងទុក

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើអោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ ស្ដីពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤
- **យោងតាមសំណើរបស់រដ្ឋមន្ត្រី *ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ***

## សំរេច

**មាត្រា ១ :** ផ្តល់ឥណទានបន្ថែមដោយផ្ទេរពីជំពូក ៤១ ‹‹ ចំណាយមិនបានគ្រោងទុក ›› នៃថវិការដ្ឋជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីផ្នែកទី ១ ជំពូក ៥០ ‹‹ ឥណទានសាងសង់ ›› ចំនួន ៦២០.៦២០.០០០ រៀល

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ — នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខា និងត្រា — ហត្ថលេខា និងត្រា

**នរោត្តម រណឫទ្ធិ** — **ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ១៩៩៤

# អនុក្រឹត្យលេខ ២២ អនក្រ ស្តីពីការបង្កើត គណៈបញ្ជាការ ឯកភាពខេត្ត ក្រុង ស្រុក ខណ្ឌ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ វរ្ម័ន**